# ព្រឹត្តិបត្រ ស្តីពីបញ្ហា អាជីវកម្ម

កម្ពុជា

លេខ ១២ មករា ២០០៧

International Finance Corporation
World Bank Group

MPDF
MEKONG PRIVATE SECTOR DEVELOPMENT FACILITY




## ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្ត[១]

*សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានការរីកចំរើនគួរឱ្យកត់សំគាល់ក្នុងរយៈកាលមួយទស្សវត្សកន្លងមកនេះ ដោយមានកំណើនជាមធ្យម ៧,១% ក្នុងមួយឆ្នាំ។[២] កំណើនសេដ្ឋកិច្ចនេះ បានជួយកាត់បន្ថយភាពក្រីក្រ ។ អត្រានៃភាពក្រីក្របានថយចុះ ពី ៤៧% ក្នុងឆ្នាំ ១៩៩៤ ទៅ ៣៥% ក្នុងឆ្នាំ ២០០៤។[៣] ក៏ប៉ុន្តែ កំណើនសេដ្ឋកិច្ចនេះមានមូលដ្ឋានចង្អៀត ដោយផ្តោតតែទៅលើវិស័យមួយចំនួនតូច និងតែលើតំបន់ទីប្រជុំជនតែប៉ុណ្ណោះ ។ ជាលទ្ធផល ការកាត់បន្ថយភាពក្រីក្រមិនបានបែងចែកស្មើគ្នាទេ ។[៤]*

*ដើម្បីធានាថាមនុស្សគ្រប់រូបបានទទួលផលប្រយោជន៍ពីកំណើនសេដ្ឋកិច្ចនេះ គេត្រូវការកំណើនសេដ្ឋកិច្ចដែលមានមូលដ្ឋានទូលំទូលាយ ។ ដោយសារសកម្មភាពអាជីវកម្មជាគន្លឹះនៃកំណើនសេដ្ឋកិច្ច គេត្រូវការបរិយាកាសអាជីវកម្មល្អទូទាំងប្រទេសសំរាប់ អភិវឌ្ឍផ្នែកឯកជន( មិនមែនតែតំបន់ទីប្រជុំជន ប៉ុណ្ណោះទេ) ដើម្បីឱ្យមានកំណើនសេដ្ឋកិច្ច បង្កើនតំរូវការការងារ និងការកាត់បន្ថយភាពក្រីក្រ ។ ដូច្នេះ មន្ត្រីរដ្ឋាភិបាលខេត្ត-ក្រុង ចាំបាច់ត្រូវយល់ដឹងអំពីបរិយាកាសអាជីវកម្ម ព្រោះទំនាក់ទំនងរវាងអាជីវកម្ម និងរដ្ឋាភិបាលកើតមានឡើងនៅថ្នាក់មូលដ្ឋាន ។*

*ដើម្បីរួមចំណែកក្នុងការស្វែងយល់អំពីបរិយាកាសអាជីវកម្មនៅថ្នាក់មូលដ្ឋាន កម្មវិធីអភិវឌ្ឍន៍វិស័យ ឯកជនតំបន់ទន្លេមេគង្គ របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ(IFC-MPDF) និងមូលនិធិអាស៊ី កំពុងធ្វើការវាយ តម្លៃបរិយាកាសអាជីវកម្មតាមខេត្តប្រចាំឆ្នាំ ពោលគឺវាយតម្លៃអភិបាលកិច្ចសេដ្ឋកិច្ចរបស់ខេត្តនានាក្នុង ប្រទេសកម្ពុជា ។ ព្រឹត្តិប័ត្រស្តីពីបញ្ហាអាជីវកម្មលេខនេះនឹងសង្ខេបអំពីលទ្ធផលនៃការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តជាលើកដំបូង ដែលផ្តល់ចំណាត់ថ្នាក់អភិបាលកិច្ចសេដ្ឋកិច្ចដល់ខេត្ត ១០ ដោយប្រើសន្ទស្សន៍ចំនួន ១០ និងពិនិត្យមើលវិស័យកំណែទម្រង់អាទិភាព ដែលមានឥទ្ធិពលលើការបង្កើតការងារ ។*

## ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តក្នុងប្រទេសកម្ពុជា ឆ្នាំ ២០០៦

*ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្ត គឺជាការវិភាគប្រៀបធៀបយ៉ាងលំអិតអំពីអភិបាលកិច្ចសេដ្ឋកិច្ច[៥] ដោយប្រើមូលដ្ឋានសំរាប់វិនិច្ឆ័យចំនួន ១០ ពោលគឺ ចំណាយដើម្បីចាប់ផ្តើមអាជីវកម្ម កម្មសិទ្ធិលើទ្រព្យសម្បត្តិ តម្លាភាព និងការទទួលបានព័ត៌មាន ការចូលរួម ចំណាយពេលដើម្បីគោរពតាមបទបញ្ញត្តិ ការចំណាយក្រៅផ្លូវការ ការទប់ស្កាត់ឧក្រិដ្ឋកម្ម ពន្ធដារ កិច្ចប្រឹងប្រែងរបស់អ្នកដឹកនាំថ្នាក់ខេត្ត និងការដោះស្រាយជំលោះ។*

MPDF
MEKONG PRIVATE SECTOR DEVELOPMENT FACILITY

**ព្រឹត្តិបត្រស្តីពីបញ្ហាអាជីវកម្ម** ផ្តល់ជូនលោកអ្នកដែលមានចំណាប់អារម្មណ៍ពីរឿងរ៉ាវទាក់ទិននឹងកិច្ចការអាជីវកម្មនូវសេចក្តីសង្ខេបខ្លីៗ និងសេចក្តីវិភាគលើប្រធានបទដែលពាក់ពន្ធ័នឹងបរិយាកាសអាជីវកម្មនៅកម្ពុជា។ ព្រឹត្តិបត្រ័នេះមានរួមបញ្ចូលទាំងមតិ និងយោបល់ផ្សេងៗ របស់មជ្ឈដ្ឋានពាក់ពន្ធ័ផងដែរ។

ព្រឹត្តិបត្រ័នេះ ត្រូវបានបោះពុម្ពឡើងដោយមានការឧបតម្ភពីសំណាក់អង្គការកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) ដែលជាស្ថាប័នពហុជំនួយគ្រប់គ្រងដោយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលជាផ្នែកឯកជននៃក្រុមធនាគារពិភពលោក។

មតិ ឬយោបល់ទាំងឡាយដែលចុះផ្សាយនៅក្នុងព្រឹត្តិប័ត្រនេះ មិនតំណាងឱ្យទស្សនៈជាផ្លូវការ របស់អង្គការកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ ឬ IFC ទេ វាគ្រាន់តែផ្តល់ជាព័ត៌មានយោងបន្ថែមតែប៉ុណ្ណោះ។

---

[១] ដរាបណាគ្មានការសំគាល់ផ្សេងទៀតទេ ព័ត៌មាននៅក្នុងព្រឹត្តិប័ត្រនេះ រួមទាំងស្ថិតិ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ទាំងឡាយ សុទ្ធតែដកស្រង់ចេញពីរបាយការណ៍ "ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តរបស់ប្រទេសកម្ពុជាឆ្នាំ ២០០៦" ធ្វើឡើងរួមគ្នាដោយ កម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC-MPDF) និងមូលនិធិអាស៊ីដែលបានទទួលការឧបត្ថម្ភផ្នែកមូលនិធិពីទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID) ។ របាយការណ៍នេះរៀបចំឡើងដោយ បណ្ឌិត Edmund Malesky ដែលជាទីប្រឹក្សារបស់គំរោងនេះ និងជាសាស្ត្រាចារ្យនៅសកលវិទ្យាល័យកាលីហ្វ័រនីញ៉ា - សែនឌីអេហ្គោ។ ការស្រាវជ្រាវនៅមូលដ្ឋានក្នុងប្រទេសកម្ពុជាធ្វើឡើងដោយ ក្រុមហ៊ុន Indochina Research Limited ។

[២] អាត្រាកំណើននេះគឺជា អាត្រាកំណើនមធ្យមក្នុងរយៈកាលពីឆ្នាំ ១៩៩៤ ដល់ ២០០៤។ ធនាគារពិភពលោក (២០០៦) *កម្ពុជា: ភាពក្រីក្រ អាចបន្ថយពាក់កណ្តាលបានទេនាឆ្នាំ ២០១៥?*

[៣] ក្នុងប្រទេសកម្ពុជា គេកំណត់បន្ទាត់នៃភាពក្រីក្រដែលជាកំរិតនៃការប្រើប្រាស់ទំនិញ និងសេវា ដែលវាស់វែងដោយចំណាយដើម្បីអាចរស់នៅបានដោយសមស្រប នៅត្រឹម ០,៤៥ ដុល្លារ ក្នុងមួយថ្ងៃ។ ធនាគារពិភពលោក (២០០៦) *កម្ពុជា: ភាពក្រីក្រ អាចបន្ថយពាក់កណ្តាលបានទេនាឆ្នាំ ២០១៥?*

[៤] ភាគច្រើននៃជនក្រីក្ររស់នៅតំបន់ជនបទ (៩១%) ។ ធនាគារពិភពលោក (២០០៦) *កម្ពុជា: ភាពក្រីក្រ អាចបន្ថយពាក់កណ្តាលបានទេនា ឆ្នាំ ២០១៥?*

[៥] អភិបាលកិច្ចសេដ្ឋកិច្ច សំដៅលើ បរិយាកាសគោលនយោបាយ ស្ថាប័ន ច្បាប់ ក្នុងសេដ្ឋកិច្ចប្រទេសមួយ។ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច មីក្រូសេដ្ឋកិច្ច និងសារពើពន្ធ ភ្នាក់ងារសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ភ្នាក់ងារ និងគោលនយោបាយបទបញ្ញត្តិនានា ច្បាប់ក្រុមហ៊ុន និងស្ថាប័ន ច្បាប់ទាំងអស់បង្កើតបានជាអភិបាលកិច្ចសេដ្ឋកិច្ចរបស់ប្រទេសមួយ។ http://www.ausaid.gov.au/hottopics/apec/ecogov.cfm

*i.* ***ចំណាយដើម្បីចាប់ផ្តើមអាជីវកម្ម*** **:** ការវាស់ស្ទង់ពេលវេលាដែលគេត្រូវការជាចាំបាច់សម្រាប់ ចុះបញ្ជីអាជីវកម្ម ការទទួលបានអាជ្ញាប័ណ្ណនានាដែលចាំបាច់ដើម្បីចាប់ផ្តើមអាជីវកម្ម ចំនួនអាជ្ញាប័ណ្ណ ដែលអាជីវកម្មត្រូវការ និងចំណាយផ្លូវការដើម្បីទទួលបានលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណទាំងនោះ ។

*ii.* ***កម្មសិទ្ធិលើទ្រព្យសម្បត្តិ*** **:** ការវាស់ស្ទង់ពីកម្មសិទ្ធិស្របច្បាប់លើអាគារដែលគេប្រើក្នុងអាជីវកម្ម និងសុវត្ថិភាពនៃកម្មសិទ្ធិនៅពេលគេទទួលបានដីធ្លី ។

*iii.* ***តម្លាភាព និងការទទួលបានព័ត៌មាន*** **:** ការវាស់ស្ទង់ថាតើក្រុមហ៊ុននានាអាចទទួលបានឯកសារផែនការត្រឹមត្រូវ និងឯកសារច្បាប់ ដែលចាំបាច់សំរាប់ធ្វើអាជីវកម្មដែរឬទេ តើគេអាចទទួលបានឯកសារទាំងនោះ គ្រប់ៗគ្នាដែរឬទេ តើគេបានផ្សព្វផ្សាយគោលនយោបាយ និងច្បាប់ថ្មីៗទៅដល់ក្រុមហ៊ុន ដែរឬទេ និងតើគេអាចព្យាករណ៍ការអនុវត្តច្បាប់ទាំងនេះបានដែរឬទេ ។

*iv.* ***ការចូលរួម*** **:** គឺផ្នែកម្ខាងទៀតនៃតម្លាភាព ដែលវាស់ស្ទង់ថាតើមានការពិគ្រោះយោបល់ជាមួយក្រុមហ៊ុនឯកជនដែរឬទេ នៅពេលគេរៀបចំគោលនយោបាយថ្នាក់ខេត្ត-ក្រុង និងថាតើផលប្រយោជន៍របស់ក្រុមហ៊ុនឯកជនត្រូវបានលើកឡើងតាមរយៈ សមាគមន៍អាជីវកម្ម ឬ ក្រុមផ្សេងៗទៀត ដែលមានផលប្រយោជន៍រួម នៅក្នុងការពិភាក្សាគោលនយោបាយដែរឬទេ ។

*v.* ***ថ្លៃដើមជាពេលវេលាដើម្បីគោរពតាមបទបញ្ញត្តិ*** **:** ការវាស់ស្ទង់ថាតើក្រុមហ៊ុនចំណាយពេលវេលាប៉ុន្មាន ដើម្បីគោរពតាមប្រព័ន្ធការិយាធិបតេយ្យ និងរយៈពេលប៉ុន្មានដើម្បីរង់ចាំ ថាតើភ្នាក់ងារត្រួតពិនិត្យនានានៅក្នុងមូលដ្ឋានធ្វើការត្រួតពិនិត្យ ក្រុមហ៊ុនញឹកញាប់កំរិតណាដែរ ។

*vi.* ***ចំណាយក្រៅផ្លូវការ*** **:** ការវាស់ស្ទង់ថាតើក្រុមហ៊ុនត្រូវចំណាយក្រៅផ្លូវការប៉ុន្មាន តើការចំណាយបន្ថែមទាំងនេះបង្កជាឧបសគ្គប៉ុណ្ណាចំពោះការធ្វើអាជីវកម្មរបស់ពួកគេ តើគេអាចព្យាករណ៍ពីចំណាយបន្ថែមនេះបានដែរឬទេ និងតើការចំណាយបន្ថែមនេះផ្តល់លទ្ធផល ឬ "សេវា" តាមការរំពឹងទុកដែរឬទេ ។

*vii.* ***ការទប់ស្កាត់ឧក្រិដ្ឋកម្ម*** **:** ការវាស់ស្ទង់ថាតើក្រុមហ៊ុនត្រូវចំណាយប៉ុន្មានលើការបាត់បង់ទ្រព្យសម្បត្តិ ដែលបណ្តាលមកពីឧក្រិដ្ឋកម្ម ឬចោរលួច តើក្រុមហ៊ុនត្រូវចំណាយប្រាក់ប៉ុន្មានលើការការពារសន្តិសុខ ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្ម ។

*viii.* ***ពន្ធដារ*** **:** ការវាស់ស្ទង់បន្ទុកខាងរដ្ឋបាល និងសារពើពន្ធ ដែលកំណត់ដោយបទបញ្ញត្តិពន្ធដារក្នុងខេត្ត ។

*ix.* ***កិច្ចប្រឹងប្រែងរបស់អ្នកដឹកនាំថ្នាក់ខេត្ត-ក្រុងក្នុងការជួយផ្នែកឯកជន*** **:** ការវាស់ស្ទង់គំនិតច្នៃប្រឌិត និងឆន្ទៈរបស់អាជ្ញាធរខេត្ត-ក្រុងនានា ក្នុងការអនុវត្តគោលនយោបាយថ្នាក់ជាតិ និងការផ្តួចផ្តើមគំនិតដោយខ្លួនឯងដើម្បីអភិវឌ្ឍផ្នែកឯកជន ក្នុងការជួយ និងការបកស្រាយបទបញ្ញត្តិជាតិដែលមានភាពមិនច្បាស់លាស់ដើម្បីជាប្រយោជន៍ក្រុមហ៊ុនឯកជននានានៅមូលដ្ឋាន ។

*x.* ***ការដោះស្រាយជំលោះ*** **:** ការវាស់ស្ទង់ការពេញចិត្តរបស់ក្រុមហ៊ុនចំពោះលទ្ធផលនៃការដោះស្រាយ ជំលោះតាមវិធីផ្លូវការ និងមិនផ្លូវការក្នុងខេត្ត-ក្រុង ។

ក្នុងឆ្នាំ ២០០៦ យើងធ្វើការអង្កេតក្នុងខេត្តចំនួន ១០ ដែលមានសកម្មភាពសេដ្ឋកិច្ចខ្លាំងក្លាជាងគេ ។ ខេត្តទាំង ១០ នោះ តំណាង ឱ្យ ៧៥ % នៃផលទុនជាតិសរុប (GDP) និង ៦៤ % នៃប្រជាជនសរុប ។ ខេត្តទាំងនោះ រួមមាន បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពត កណ្តាល ភ្នំពេញ សៀមរាប ក្រុងព្រះសីហនុ និងស្វាយរៀង ។

ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តគឺគ្រាន់តែជាការវាស់ស្ទង់អភិបាលកិច្ចសេដ្ឋកិច្ច និងគោលនយោបាយបទបញ្ញត្តិតែប៉ុណ្ណោះ ។ វាមិនវាស់ស្ទង់បរិយាកាសវិនិយោគនៅតាមខេត្តនោះទេ ដែលរួមមានទាំងការវាស់ស្ទង់អភិបាលកិច្ច និងការវាស់ស្ទង់ភាពអំណោយផលដែលមានស្រាប់ ឧទាហរណ៍ គុណភាពនៃហេដ្ឋារចនាសម្ព័ន្ធ គុណភាពនៃធនធានមនុស្ស ។ ខេត្តដូចជា ខេត្តសៀមរាប ខេត្តកំពត និង ក្រុងភ្នំពេញ ក្រុងព្រះសីហនុ មានភាពអំណោយផលដែលមានស្រាប់ល្អជាងខេត្តដទៃទៀត ហេតុដូច្នេះហើយ ចំណាត់ថ្នាក់ដែលរួមបញ្ចូលទាំងភាពអំណោយផលដែលមានស្រាប់ ផ្តល់ព័ត៌មានថ្មីៗតិចតួចប៉ុណ្ណោះដល់អ្នករៀបចំគោលនយោបាយ ។ ដោយមិនរាប់បញ្ចូលភាពអំណោយផលដែលមានស្រាប់ ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តអាចជួយឱ្យយើងកំណត់បាននូវទិដ្ឋភាពមួយចំនួននៃអភិបាលកិច្ចសេដ្ឋកិច្ច ដែលយើងអាចកែលំអបានក្នុងតំម្លៃទាប និងក្នុងរយៈពេលមធ្យម ។

លទ្ធផលចុងក្រោយនៃការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្ត មានបង្ហាញជូននៅក្នុងរូបទី ១ ខាងក្រោម ។ ខេត្តកំពង់ចាម និងស្វាយរៀង មានចំណាត់ថ្នាក់លើគេ បន្ទាប់មកគឺ ខេត្តកំពង់ឆ្នាំង និងកំពត ស្ថិតនៅលំដាប់ថ្នាក់លេខ ៣ និងលេខ ៤ ។ ខេត្តកណ្តាលមានចំណាត់ថ្នាក់លេខ ៥ បន្ទាប់មក ខេត្តបាត់ដំបង ហើយ ខេត្តបន្ទាយមានជ័យមានចំណាត់ថ្នាក់រៀងគ្នាទី ៦ និងទី ៧ ។ បណ្តាខេត្ត-ក្រុងដែលមានអភិបាលកិច្ចខ្សោយជាងគេគឺ ភ្នំពេញ ខេត្តសៀមរាប និងក្រុងព្រះសីហនុ ។

**រូបទី ១: ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្ត**




ទិន្នន័យប្រមូលបានពីការអង្កេតបរិយាកាសអាជីវកម្មតាមខេត្ត ឆ្នាំ ២០០៦

រូបទី ២ បង្ហាញអោយឃើញពីចំណុចខ្សោយ និងចំណុចខ្លាំងនៃខេត្តនីមួយៗ បើគេធៀបនឹងពិន្ទុល្អឥតខ្ចោះ ។ គ្មានខេត្តណាមួយដែលបានពិន្ទុល្អ សម្រាប់គ្រប់សន្ទស្សន៍ទាំងអស់នោះទេ ។ សូម្បីតែខេត្ត កំពង់ចាមដែលមានចំណាត់ថ្នាក់លើគេ ក៏មានពិន្ទុទាបសំរាប់សន្ទស្សន៍មួយចំនួនដែរ ដូចជា *ចំណាយក្រៅផ្លូវការ កិច្ចប្រឹងប្រែងរបស់អ្នកដឹកនាំថ្នាក់ខេត្តក្នុងការជួយផ្នែកឯកជន និងការដោះស្រាយជំលោះ* ។ ខេត្តបាត់ដំបង និងកំពង់ឆ្នាំង មានពិន្ទុអភិបាលកិច្ចមិនស្របគ្នាទេ ដោយសន្ទស្សន៍ខ្លះបានពិន្ទុល្អប្រសើរ ប៉ុន្តែខ្លះទៀតទាមទារឱ្យមានកំណែលំអយ៉ាងច្រើន ។ ខេត្ត-ក្រុងនានាដែលមានពិន្ទុទាបជាងគេ ទាមទារឱ្យគេធ្វើការកែលំអលើគ្រប់សន្ទស្សន៍ទាំងអស់ ។

**រូបទី ២: ក្រាហ្វិកអំពីពិន្ទុប្រចាំខេត្តសម្រាប់សន្ទស្សន៍នីមួយៗ**




*គោលបំណងចំបងនៃការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តនេះ ស្របតាមគោលបំណង របស់ក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមដែរ ។ ការយកចិត្តទុកដាក់ទៅលើស្ថានភាពនៃការធ្វើអាជីវកម្មរបស់សហគ្រាសធុនតូច និងមធ្យម ជាពិសេសពិនិត្យទៅលើបញ្ហាអភិបាលកិច្ចសេដ្ឋកិច្ចទាំងឡាយនៅក្នុងបណ្តាខេត្តទាំង ១០ ពិតជាឧបករណ៍ប្រកបដោយប្រសិទ្ធិភាពសម្រាប់ អង្គភាពរដ្ឋ និងឯកជន នៅតាមខេត្តនីមួយៗ ក្នុងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសអាជីវកម្ម និងលើកកម្ពស់កំរិតរីកចម្រើនសេដ្ឋកិច្ចនៅក្នុងខេត្ត របស់ខ្លួន ។*

*ខ្ញុំសូមគាំទ្រចំពោះកិច្ចសហការរួមគ្នារវាងIFC-MPDF មូលនិធិអាស៊ី និង AusAID ហើយយើងនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា ជាពិសេសជាមួយមជ្ឈដ្ឋានពាក់ព័ន្ធតាមបណ្តាខេត្ត-ក្រុងទាំងអស់ ដើម្បីឱ្យអ្វីដែលរកឃើញតាមរយៈនៃការសិក្សាស្រាវជ្រាវនេះក្លាយជាផែនការ និងកម្មវិធីដាក់លាក់ ដើម្បីធ្វើឱ្យបរិយាកាសអាជីវកម្មរបស់សហគ្រាសធុនតូច និងមធ្យម ប្រសើរឡើងនៅកំរិតមូលដ្ឋាន និងទូទាំងប្រទេស ។*

**ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល**

*ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្ត គឺជារបាយការណ៍ទាន់ពេលវេលា ព្រោះក្នុងពេលបច្ចុប្បន្ននេះអាជ្ញាធរខេត្តនានាអាចសំរេចយល់ព្រមលើគំរោងវិនិយោគដែលមានតម្លៃរហូតដល់ ២លាន ដុល្លារ ។ រដ្ឋាភិបាលក៏កំពុងធ្វើសេចក្តីព្រាងច្បាប់ស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ដែលនេះផ្តល់ការសំរេចចិត្ត កាន់តែច្រើនថែមទៀតដល់អាជ្ញាធរខេត្តនៅពេលអនាគត ។*

*គំហើញដែលគួរឱ្យចាប់អារម្មណ៍មួយ គឺខេត្តក្រីក្រខ្លះ ដូចជាខេត្តស្វាយរៀង និងកំពង់ចាម មានបរិយាកាសអាជីវកម្មល្អជាងខេត្តខ្លះដែលមានស្ថានភាពសេដ្ឋកិច្ចល្អ ដូចជា ខេត្តសៀមរាប ក្រុងភ្នំពេញ និងក្រុងព្រះសីហនុ ។ នេះជាដំណឹងដែលមានការលើកទឹកចិត្ត ព្រោះទោះជាខេត្តដែលមានសកម្មភាពសេដ្ឋកិច្ចល្អមានភាពអំណោយផលពីធម្មជាតិ ( ហេដ្ឋារចនាសម្ព័ន្ធល្អ ប្រសើរ ការចូលទៅទីផ្សារល្អប្រសើរ) ក៏ដោយក៏គំហើញនេះបង្ហាញថា ខេត្តដែលមានសេដ្ឋកិច្ចទន់ខ្សោយ អាចប្រកួតប្រជែងជាមួយ ខេត្តដែលមានសេដ្ឋកិច្ចខ្លាំងខាងផ្នែកអភិបាលកិច្ចបានដែរ ។ យើងសង្ឃឹមថាការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្ត នឹងចាប់ផ្តើមជំរុញឱ្យមានការប្រកួតប្រជែងរវាងខេត្តនានា ក្នុងការកែលំអបរិយាកាសអាជីវកម្ម និងធ្វើឱ្យមានកំណើនសេដ្ឋកិច្ច បង្កើតការងារដែលអាចនាំឱ្យមានការកាត់បន្ថយភាពក្រីក្របានឆាប់រហ័ស ។*

**លោកស្រីNisha Agrawal នាយិកាគ្រប់គ្រង ធនាគារពិភពលោក ប្រចាំប្រទេសកម្ពុជា**

*ការវាយតម្លៃបរិយាកាសអាជីកម្មតាមខេត្តវាស់ស្ទង់ពីអភិបាលកិច្ចសេដ្ឋកិច្ចតាមខេត្ត១០ ក្នុងប្រទេសកម្ពុជា ។ វាឆ្លុះបញ្ចាំងនូវ ការយល់ឃើញរបស់ផ្នែកឯកជនអំពីលទ្ធផលនៃការងាររបស់រដ្ឋបាលខេត្តនានា ក្នុងការធ្វើឱ្យបរិយាកាសអាជីកម្មប្រសើរឡើង ។ យើងសង្ឃឹមថា ការវាយតម្លៃនេះនឹងក្លាយជា ឧបករណ៍យ៉ាងសំខាន់ ក្នុងការជួយឱ្យអាជ្ញាធរអាចដឹងថាតើគេត្រូវប្រឹងប្រែងកំរិតណា ក្នុងការកែលំអ បទបញ្ញត្តិនៅថ្នាក់មូលដ្ឋាន និងអនុវត្តច្បាប់ជាតិ ។ ការវិភាគរបស់ យើងបង្ហាញថា ការកែទំរង់ក្នុងវិស័យទាំង ១០( ជាពិសេសចំណាយក្រៅផ្លូវការ និងកម្មសិទ្ធលើទ្រព្យសម្បត្តិ) អាចនឹងនាំឱ្យអាជីវកម្មរីកចំរើន និងបង្កើតការងារច្រើនទៀត ។*

**សាស្ត្រាចារ្យEdmund Malesky ទីប្រឹក្សាគំរោង ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្ត ក្នុងប្រទេសកម្ពុជា**

*លក្ខណៈវិនិច្ឆ័យខ្លះដែលការសិក្សារអំពីការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តនេះបានប្រើ ដើម្បីវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្ត-ក្រុងមិនឆ្លុះបញ្ចាំងអភិបាលកិច្ចក្នុងខេត្ត-ក្រុងទេ ព្រោះ លក្ខណៈវិនិច្ឆ័យខ្លះមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុងទេ ប៉ុន្តែស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋាភិបាលថ្នាក់ជាតិ ។ ឧទាហរណ៍ ការប្រមូលពន្ធដារ មិនស្ថិតក្រោមសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុងទេ ។*

**លោក សួន វិនឌី នាយរងខុទ្ទកាល័យ រាជធានីភ្នំពេញ**

*សំរាប់ខេត្តកំពង់ចាម ខ្ញុំយល់ស្របជាមួយគំហើញដែលថា ខេត្តមានចំណុចខ្លាំង៧ និងចំណុចខ្សោយ៣ ។ សន្ទស្សន៍ទាំងអស់សុទ្ធតែមានសារៈសំខាន់ក្នុងការកែលំអបរិយាកាសអាជីវកម្ម ។ ដូច្នេះ ខេត្តកំពង់ចាមនឹងប្រឹងប្រែងធ្វើការកែលំអសន្ទស្សន៍ទាំងអស់ ។ ក៏ប៉ុន្តែ យើងនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយផ្នែកឯកជន ផ្តល់អាទិភាពដល់ការកែលំអសន្ទស្សន៍៣ ដែលមិនទាន់បានពិន្ទុល្អ ។*

*ប្រសិនបើមានជំនួយបច្ចេកទេសពីភ្នាក់ងារផ្តល់ជំនួយ យើងរីករាយនឹងស្វាគមន៍ ។ យើងត្រៀមខ្លួន ដើម្បីធ្វើការជាមួយភ្នាក់ងារផ្តល់ជំនួយ និងវិស័យឯកជនដើម្បីកែលំអបរិយាកាសអាជីវកម្ម ក្នុងខេត្ត ។*

**លោក យិន ប៊ុនទិត អគ្គលេខាធិការ ខេត្តកំពង់ចាម**

*ខ្ញុំសូមស្វាគមន៍និងគាំទ្រដល់លទ្ធផល និងអនុសាសន៍ នៃការសិក្សាអំពីការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្ត ដែលបានធ្វើឡើងដោយ IFC-MPDF និងមូលនិធិអាស៊ី ។ ខ្ញុំគាំទ្រឱ្យមានការផ្សព្វផ្សាយបន្ថែមទៀត តាមរយៈការតស៊ូមតិ និងពិភាក្សាដោះស្រាយរវាងអជ្ញាធរជាមួយនិងគំនិតសមូហភាពរបស់សមាគមន៍នានា ។*

*ខ្ញុំនឹងលើកគំរោងធ្វើការកែទម្រង់លើវិស័យពីរជូនទៅអាជ្ញាធរខេត្ត ។ ទីមួយគឺការកែទម្រង់សេវា សាធារណៈដោយកាត់បន្ថយនិតិវិធី និងពេលវេលាសុំអាជ្ញាប័ណ្ណសំរាប់ធ្វើអាជីកម្ម និងការចំណាយលើការ សុំអាជ្ញាប័ណ្ណសំរាប់ធ្វើអាជីវកម្ម ។ កំណែទម្រង់ ទីពីរ គឺទាក់ទងនឹងតម្លាភាព ។ យើងនឹងធ្វើការផ្សព្វផ្សាយ ច្បាប់ផ្សេងៗដែលទាក់ទង នឹងការធ្វើអាជីវកម្មបន្ថែមទៀត ។*

**លោក ឈុន ហ៊ីន ប្រធានមន្ទីរ ឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពត**

*ខ្ញុំគិតថាបន្ទាពន្ធដារក្នុងខេត្តកំពង់ចាមគឺសមហេតុផលសំរាប់អាជីវករហើយ ។ ក៏ប៉ុន្តែ ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តបានរកឃើញថា ប្រហែល ៨៤% នៃ ក្រុមហ៊ុនក្នុងខេត្តកំពង់ចាម ចាត់ទុកថាការបង់សំណូកទៅឱ្យមន្ត្រីពន្ធគឺជាឧបសគ្គសំខាន់មួយ ។ ការរកឃើញនេះហាក់ដូចជាមិនឆ្លុះបញ្ចាំងអំពីស្ថានភាពបង់ពន្ធដារក្នុងខេត្តកំពង់ចាមទេ ។*

*អ្វីដែលសំខាន់ជាងនេះគឺ ក្នុងខេត្តកំពង់ចាម មានអាជីវកម្មជាច្រើន ដែលធ្វើសកម្មភាពមិនផ្លូវការ នេះរារាំងមិនឱ្យមានការប្រកួតប្រជែងយុត្តិធមិ ចំពោះក្រុមហ៊ុនដែលបានចុះបញ្ជីជាផ្លូវការនោះទេ ។ ខ្ញុំគិតថា ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្ត គួរតែលើកបញ្ហានេះឡើង ។*

**លោក បាញ់ ឡេង ប្រធានសមាគមន៍ SME ខេត្តកំពង់ចាម**

## ឥទ្ធិពលនៃបរិយាកាសអាជីវកម្មតាមខេត្តទៅលើអាជីវកម្ម

ការវិភាគស្ថិតិនៃការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តបានបង្ហាញថា ការកែលំអបរិយាកាសអាជីវកម្មនាំឱ្យមានការពង្រីកក្រុមហ៊ុន និងបង្កើតការងារ ។ បើខេត្តដែលមានចំណាត់ថ្នាក់មធ្យម កែលំអអភិបាលកិច្ចសេដ្ឋកិច្ចឱ្យបានពិន្ទុដូចខេត្តដែលមានចំណាត់ថ្នាក់លើគេ ក្រុមហ៊ុនក្នុងខេត្តនោះអាចនឹងពង្រីកសកម្មភាពអាជីវកម្មរបស់ខ្លួនកាន់តែច្រើនឡើង ។ ឧទាហរណ៍ បើខេត្តបាត់ដំបងកែលំអបរិយាកាស អាជីវកម្មបច្ចុប្បន្នរបស់ខ្លួនដែលមានពិន្ទុ ៥៦,៤៦ ឱ្យបានដូចបរិយាកាសអាជីវកម្មខេត្តកំពង់ចាម ដែលមានពិន្ទុ ៧២,៩ លទ្ធភាពដែលក្រុមហ៊ុនក្នុងខេត្តបាត់ដំបងពង្រីកអាជីវកម្មរបស់ខ្លួនកើនឡើង១៧% ។

ទិន្នន័យរបស់ការវាយតម្លៃបរិយាកាសអាជីវកម្មក៏បានបង្ហាញផងដែរថា អភិបាលកិច្ចសេដ្ឋកិច្ចប្រសើរនឹងបង្កើតការងារបន្ថែមទៀត ។ ឧទាហរណ៍ បើខេត្តបន្ទាយមានជ័យ កែលំអពិន្ទុអភិបាលកិច្ចរបស់ខ្លួន ឱ្យដូចខេត្តកំពង់ឆ្នាំង គេរំពឹងថាក្រុមហ៊ុនក្នុងខេត្តបន្ទាយមានជ័យអាចនឹងជួលបុគ្គលិកបន្ថែម ១៣% ទៀត ។

*ក្នុងខេត្តកំពត ចំណុចដែលអាជ្ញាធរគួរកែលំអរួមមានពីរសំខាន់ៗគឺ* តម្លាភាព និងចំណាយក្រៅផ្លូវការ ។ *ពាក់ព័ន្ធនិងតម្លាភាព មិនមានការប្រកាសអំពីច្បាប់ និងនិតិវិធីផ្សេងៗឱ្យអាជីវករបានដឹង ដើម្បីសំរួលដល់ការធ្វើ អាជីវកម្មទេ ។ ក្នុងការធ្វើអាជីវកម្មសព្វថ្ងៃនេះ អាជីវករត្រូវបង់ចំណាយក្រៅ ផ្លូវការទៅឱ្យនគរបាល មន្ត្រីពន្ធដារ ហើយទាំងនេះធ្វើឱ្យការធ្វើអាជីវកម្មមានការលំបាក ។*

*ខ្ញុំជឿជាក់ថា ប្រសិនបើអាជ្ញាធរអាចធ្វើឱ្យមានតម្លាភាព និងកាត់បន្ថយចំណាយក្រៅផ្លូវការបាន នោះការធ្វើអាជីវកម្មក្នុងខេត្តកំពតនឹងមានភាពល្អប្រសើរ ។ ជាលទ្ធផល ខ្ញុំជឿជាក់ថា អាជីវករនឹងពង្រីកអាជីវកម្មរបស់ខ្លួនជាពិសេសវិស័យ SME ដែលមានសក្តានុពលក្នុងការរីកចំរើន ហើយនឹងជួលបុគ្គលិកដែលជាជនក្រីក្រនៅក្នុងខេត្តនេះ ។ នេះជាការរួមចំណែកយ៉ាងធំក្នុងការកាត់បន្ថយភាពក្រីក្រ ។*

**លោក ទុន សាខន អនុប្រធានសមាគមន៍ SME ខេត្តកំពត**

ថ្វីបើយើងទទួលស្គាល់ថា ការកែលំអបរិយាកាសអាជីវកម្មជាការងារលំបាក បទពិសោធន៍របស់សាជីវកម្មអន្តរជាតិពីប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនបង្ហាញថា គេអាចសំរេចការងារនេះបាន ។ ឧទាហរណ៍ ក្នុងឆ្នាំ២០០១ កំណែទម្រង់បានកាត់បន្ថយថ្លៃដើម និងពេលវេលាយ៉ាងច្រើន ក្នុងការទទួលបានអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតិអាជីវកម្មក្នុងទីក្រុងគេហ្សូន ប្រទេសភីលីពីន ។ ក្នុងទីក្រុង ឡាប៉ាស ប្រទេសបូលីវៀ បន្ទាប់ពីរយៈពេលមួយឆ្នាំ ដែលសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិបានផ្តល់ជំនួយបច្ចេកទេស ដើម្បីសំរួលការចុះបញ្ជីអាជីវកម្ម ពេលវេលាដើម្បីទទួលបានអាជ្ញាប័ណ្ណសំរាប់ធ្វើអាជីវកម្មលឿនជាងមុន ១៣ ដង ។[៦]

## សេចក្តីសន្និដ្ឋាន

ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តឆ្នាំ២០០៦ មានការសន្និដ្ឋានសំខាន់ៗបី ។ ទីមួយ អភិបាលកិច្ចថ្នាក់ខេត្ត ដែលការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តបានវាស់ស្ទង់ មានភាពខុសគ្នា យ៉ាងខ្លាំងនៅតាមខេត្តផ្សេងៗ ក្នុងប្រទេសកម្ពុជា ។

ទីពីរ ខេត្តទាំងអស់មានការងារច្រើនដែលត្រូវធ្វើ ដើម្បីកែលំអអភិបាលកិច្ច ទោះបីជាមានពិន្ទុខ្ពស់ក៏ដោយ ។ មិនមានខេត្តណាមួយបានពិន្ទុល្អឥតខ្ចោះទេ ។ ចំពោះខេត្តដែលទទួលបានលទ្ធផលល្អ គេត្រូវកែលំអលើវិស័យអាទិភាពមួយចំនួនតូច ។ ខេត្តដែលទទួលបានលទ្ធផលមិនសូវល្អ ត្រូវកែលំអគោលនយោបាយបទបញ្ញត្តិ និងអភិបាលកិច្ចសេដ្ឋកិច្ចលើគ្រប់ វិស័យទាំងអស់ ។

ការកែលំអលើអភិបាលកិច្ចណាមួយក៏អាចមានឥទ្ធិពលខ្លាំងទៅលើការពង្រីកអាជីវកម្ម និងបង្កើត ការងារនៅតាមខេត្តដែរ ។ ប៉ុន្តែការកែលំអវិស័យមួយចំនួនតូចនឹងទទួលបានលទ្ធផលច្រើន ។ ការវិភាគស្ថិតិ របស់ការវាយតម្លៃបរិយាកាសអាជីវកម្ម បង្ហាញថា ការកែលំអក្នុងវិស័យ *ចំណាយដើម្បី ចាប់ផ្តើមអាជីវកម្ម សិទ្ធិលើទ្រព្យសម្បត្តិ ការចូលរួម ចំណាយក្រៅផ្លូវការ* និង*ការដោះស្រាយជំលោះ* នឹងបង្កើតការងារច្រើនជាងការកែលំអក្នុងវិស័យផ្សេងទៀត ។

៦ *ការសំរួលបទបញ្ញត្តិអាជីវកម្មនៅថ្នាក់ខេត្ត-ក្រុង: ឧបករណ៍សំរាប់អនុវត្តការកែទំរង់សំរាប់ក្រុមអនុវត្តគំរោងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ* (២០០៦) ទំព័រ ១០៤ និង ១១៥


រក្សាសិទ្ធិ MPDF 2007
Publisher: MPDF No. 70, Norodom Blvd., Phnom Penh
Tel: (855)-23-210-922 Fax: (855)-23-215-157
E-mail: shor@ifc.org Website: www.mpdf.org
Layout by: Kea Kunthea
Printed by: MAKARA Printing House